ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

ឯកឧត្តម ឡុង វិសាលោ រដ្ឋមន្ត្រីស្តីទី ធ្វើសន្និសីទព័ត៌មាន
ស្តីពីលទ្ធផលជំនួបរវាងសម្តេចតេជោនាយករដ្ឋមន្ត្រីហ៊ុន សែន
និងឯកឧត្តម យ៉ាង ជាឈី ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន

នៅរសៀលថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង ៣៖០០ ឯកឧត្តម ឡុង វិសាលោ រដ្ឋមន្ត្រីស្តីទី បានធ្វើសន្និសីទព័ត៌មាននៅទីស្តីការក្រសួង ស្តីពីលទ្ធផលជំនួបរវាងសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឯកឧត្តម យ៉ាង ជាឈី ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសដែលឯកឧត្តមមកបំពេញទស្សនកិច្ចផ្លូវការ និងចូលរួមជាសហប្រធាននៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន លើកទី៤ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង នៅទីក្រុងភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧។

ឯកឧត្តម យ៉ាង ជាឈី ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន បានថ្លែងអំណរគុណយ៉ាងខ្លាំងចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលសម្តេចបានពន្យារពេលនិងអនុញ្ញាតអោយឯកឧត្តមចូលជួបសំដែងការគួរសម មុនពេលដែលសម្តេចតេជោអញ្ជើញចាកចេញពីកម្ពុជាទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាននៅហ្វីលីពីន។

ខ្លឹមសារសំខាន់ៗនៃជំនួបរវាងសម្តេចតេជោនាយករដ្ឋមន្ត្រី និងឯកឧត្តម យ៉ាង ជាឈី ទីប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន មានដូចតទៅ៖

-ភាគីចិននៅតែបន្តការគាំទ្រតំបន់សេដ្ឋកិច្ចពិសេសនៅកំពង់សោម

-ខិតខំបន្តការសាងសង់ផ្លូវល្បឿនលឿនពីភ្នំពេញទៅក្រុងព្រះសីហនុ

-ការសាងសង់វាលយន្តហោះនៅខេត្តសៀមរាប

គម្រោងទាំងអស់នេះសុទ្ធសឹងតែជានិមិត្តរូបនៃទំនាក់ទំនងរវាងចិន និងកម្ពុជា។

ឯកឧត្តម យ៉ាង ជាឈី បានជំរាបជូនសម្តេចតេជោនាយករដ្ឋមន្ត្រីថា ដល់ឆ្នាំ២០២០អាចមានចំនួនអ្នកទេសចរចិនប្រហែលជាពីរលាននាក់ក្នុងមួយឆ្នាំមកកម្ពុជា ហើយឯកឧត្តមកាន់តែសង្ឃឹមច្បាស់លាស់ថាពេលនោះប្រជាជនកម្ពុជា និងចិនកាន់តែយល់គ្នា ស្គាល់គ្នាច្បាស់ឡើងមួយកំរិតថែមទៀត។

ឯកឧត្តម យ៉ាង ជាឈី បានលើកឡើងថា កម្ពុជានឹងធ្វើការបោះឆ្នោតឃុំ-សង្កាត់ និងការបោះឆ្នោតជាសកលនៅកម្ពុជា ឆ្នាំក្រោយនេះនឹងប្រកបដោយភាពយុត្តិធម៌ និងត្រឹមត្រូវ។ ពាក់ពន្ធ័និងបញ្ហានេះដែរ ឯកឧត្តមក៏បានលើកឡើងថា ឯកឧត្តមកំពុងតែខិតខំសម្រុះសម្រួលជាមួយនឹងសហគ្រាសចិន ដើម្បីរិះរកវិធីប្រើប្រាស់ថវិការដែលជាជំនួយឥតសំណងរបស់ចិនមកកម្ពុជាចំនួនបីពាន់ប្រាំមួយរយលានយាន់ សំរាប់ឆ្នាំ២០១៦-២០១៨នេះ ឲ្យបានទាន់ពេលវេលា និងចំទិសដៅដែលប្រជាពលរដ្ឋកម្ពុជាចង់បានទៀតផង។ គំរោងទាំងនោះសព្វថ្ងៃអ្នកជំនាញចិនកំពុងមកធ្វើការសិក្សាស្រាវជ្រាវឲ្យកាន់តែច្បាស់ថែមទៀត ហើយក៏ឃើញថាមានការដ្ឋានមួយចំនួនបានបើកសម្ពោធរួចហើយ ដូចជា ការជីកអណ្តូងទឹក ការធ្វើផ្លូវ។ ភាគីចិនក៏បានវាយតម្លៃថាភាគីកម្ពុជាបានយកចិត្តទុកដាក់ប្រើប្រាស់គំរោងរបស់ភាគីចិនបានល្អ។ ភាគីចិនបានបញ្ជាក់ថាចិនគាំទ្រកម្ពុជាធ្វើយ៉ាងណារក្សាអោយបាននូវសន្តិភាពនិងសន្តិសុខនៅកម្ពុជា។

ឯកឧត្តម យ៉ាង ជាឈី ក៏បានជំរាបជូនសម្តេចអគ្គមហាសេនាបតីតេជោ អំពីសមុទ្រចិនខាងត្បូងថាសឹងមិនមានជាបញ្ហាអ្វីទេ ព្រោះសព្វថ្ងៃទំនាក់ទំនងចិនជាមួយហ្វីលីពីនក៏បានល្អ ហើយ លោក ស៊ី ជីនពីងក៏ទើបតែមកពីទស្សនកិច្ចនៅអាមេរិក ហើយអាមេរិកក៏មានទំនាក់ទំនងល្អជាមួយគាត់ ហើយប្រហែលជាអាចពីរឆ្នាំទៀតលោកដូណាល់ត្រាំ នឹងទៅទស្សនកិច្ចនៅស្រុកចិន ហើយឯកឧត្តមបានបញ្ជាក់ថាសព្វថ្ងៃកិច្ចសហប្រតិបត្តិការវាងអាមេរិក និងចិន មានច្រើនវិស័យហើយ។ ដោយសារតែទំនាក់ទំនងរវាងអាមេរិកនិងចិនមានការវិវត្តល្អ ឯកឧត្តមយ៉ាង ជាឈី សង្ឃឹមថាកិច្ចប្រជុំកំពូលអាស៊ានដែលធ្វើនៅទីក្រុងម៉ានីលនឹងបានលទ្ធផលប្រកបដោយជោគជ័យ និងផ្លែផ្កា មិនមានបញ្ហាអ្វីឡើយ តែក៏មិនភ្លេចថានៅមានប្រទេសខ្លះនៅតែមានបំណងចង់កកូរកកាយនៅក្នុងអាស៊ានដែរ តែយ៉ាងណាយើងខិតខំធ្វើអោយមានការឯកភាពគ្នានៅក្នុងរង្វង់អាស៊ាន និងប្រុងប្រយ័ត្នចំពោះចំណុចអវិជ្ជមាន។

ឯកឧត្តម យ៉ាង ជាឈី បានលើកសរសើរសម្តេចតេជោ ថាជាអ្នកនយោបាយដ៏កំពូលនៅអាស៊ីអាគ្នេយ៍នេះ ហើយឯកឧត្តមគាំទ្រគ្រប់ពេលវេលានូវប្រសាសន៍របស់សម្តេចតេជោ ។

សម្តេចអគ្គមហាសេនាបតីតេជោ បានឆ្លើយតបថា សម្តេចបានយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះកិច្ចសហប្រតិបត្តិការដែលមានការអភិវឌ្ឍមួយចំនួនរួចមកហើយ ពិសេសការត្រៀមសហការគ្នាតទៅមុខទៀតអំពីបញ្ហា "ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ" ដោយសម្តេចបានគិតគូរថានឹងលើកគម្រោងនៅកម្ពុជាមួយចំនួនដាក់ក្នុងក្របខ័ណ្ឌ "ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ" គម្រោងទាំងនោះរួមមាន តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ ការសាងសង់ផ្លូវល្បឿនលឿនពីភ្នំពេញទៅខេត្តព្រះសីហនុ និងការសាងសង់វាលយន្តហោះថ្មីនៅខេត្តសៀមរាប។ សម្តេច បានបន្ថែមថា បញ្ហាអគ្គិសនីនៅកម្ពុជាក៏គួរតែសិក្សាដើម្បីដាក់បញ្ចូលទៅក្នុងក្របខ័ណ្ឌ "ផ្លូវមួយ ខ្សែក្រវ៉ាត់មួយ" ដើម្បីឲ្យឃើញថា គំនិតផ្តួចផ្តើមរបស់ប្រធានាធិបតី ស៊ី នឹងបម្រើផលប្រយោជន៍ប្រជាជនកម្ពុជាដែរ។

ពាក់ព័ន្ធបញ្ហាកិច្ចប្រជុំកំពូលអាស៊ាននៅទីក្រុងម៉ានីល សម្តេចអគ្គមហាសេនាបតីតេជោ បានលើកឡើងថា មានប្រទេសអាស៊ានខ្លះគេក៏គិតអំពីផលប្រយោជន៍របស់ខ្លួនគេ ដូច្នេះបញ្ហានេះកម្ពុជាក៏ត្រូវតែប្រុងប្រយ័ត្នចំណុចអវិជ្ជមានដែរ។

ពាក់ព័ន្ធបញ្ហាការបោះឆ្នោត សម្តេចអគ្គមហាសេនាបតីតេជោ បានលើកឡើងថា បើគិតពីសមាជិកនៃគណបក្សប្រជាជនកម្ពុជាតាមចំនួនដែលមាន បើសិនជាសមាជិកម្នាក់បោះឆ្នោតបានមួយសម្លេង ហើយបូកជាមួយសម្លេងរបស់សមាជិកក្រុមគ្រួសារទៀត នោះគណបក្សប្រជាជនអាចនឹងឈ្នះ។

ចំណែកឯ បញ្ហានៅសមុទ្រចិនខាងត្បូង សម្តេចអគ្គមហាសេនាបតីតេជោ បានមានប្រសាសន៍ថា គណបក្សប្រជាជនកម្ពុជាពុំរាថយជាច់ខាតទោះស្ថិតនៅក្នុងតម្លៃណាក៏ដោយ គឺជំហររបស់កម្ពុជាពាក់ព័ន្ធបញ្ហាសមុទ្រចិនខាងត្បូងនៅតែដដែល ព្រោះនេះជាបញ្ហាសន្តិសុខតំបន់ មិនមែនជាបញ្ហារបស់កម្ពុជាតែម្នាក់ឯងទេ។ សម្តេចបានលើកឡើងថា បញ្ហាសមុទ្រចិនខាងត្បូងមានសណ្ឋានពីរគឺៈ ទីមួយសមាជិកអាស៊ានទាំងអស់ និងប្រទេសសមាជិកជាដៃគូ ត្រូវខិតខំធ្វើយ៉ាងណាអនុវត្តឲ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវ DOC និងរៀបចំធ្វើ COC ទៅមុខទៀត នេះជារឿងរបស់អាស៊ាន រីឯការសម្រេចរបស់តុលាការមជ្ឈឹតកម្មអន្តរជាតិនោះ ជារឿងរបស់ហ្វីលីពីន។ សម្តេចក៏បានលើកឡើងថា បើគេនៅតែនាំគ្នាលើកអំពីបញ្ហាសមុទ្រចិនខាងត្បូង សម្តេចត្រូវតែធ្វើបឋកថាមួយពន្យល់អំពីអ្វីទៅដែលហៅថា "សមុទ្រចិនខាងត្បូង" តែសម្តេចសង្ឃឹមថាមិនដល់ថ្នាក់នោះទេ ព្រោះសព្វថ្ងៃសភាពការណ៍ល្អហើយ។

តាមការវាយតម្លៃរបស់ភាគីចិន សម្តេចអគ្គមហាសេនាបតីតេជោ ក៏បានឯកភាពចំពោះទំនាក់ទំនងដ៏ល្អរវាងចិន និងហ្វីលីពីន ព្រមទាំងចិន និងវៀតណាម ហើយវៀតណាមក៏មានជំហរចង់រកដំណោះស្រាយឲ្យបានល្អ ពាក់ព័ន្ធនឹងបញ្ហាសមុទ្រចិនខាងត្បូងនេះដែរ។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៧